**សេចក្ដីប្រកាសសារព័ត៌មាន**

**ហាមចេញផ្សាយរហូតដល់ ថ្ងៃចន្ទ ទី ១០ ខែ មិថុនា ឆ្នាំ ២០១៩**
**វេលាម៉ោង ០០.០១ ព្រឹក**

# សហគ្រាសអនុផលព្រៃឈើដោយសហគមន៍មូលដ្ឋាន
# បង្កើតឱ្យមានការលើកទឹកចិត្តចំពោះកិច្ចគាំពារសង្គម និងបរិស្ថាន

*ក្រុងភ្នំពេញ ថ្ងៃចន្ទ ទី ១០ ខែ មិថុនា ឆ្នាំ ២០១៩៖* ក្រុមផលិតករ និងសមាគមអនុផលព្រៃឈើ គឺជាអ្នកផ្ដល់កិច្ចគាំពារសង្គមដ៏សំខាន់ ហើយទន្ទឹមនឹងនោះ ពួកគេក៏រួមចំណែកយ៉ាងច្រើនដល់ការសម្រេចគោលដៅអភិរក្សព្រៃឈើ និងលុបបំបាត់ភាពក្រីក្រផងដែរ។ ជាក់ស្ដែង ៦៨% នៃគ្រួសារជនបទ ទូទាំងប្រទេសកម្ពុជា ពឹងអាស្រ័យលើធនធានព្រៃឈើ សម្រាប់សកម្មភាពជីវភាពរស់នៅរបស់ខ្លួន។ ក្រៅពីការប្រមូលផលដំណាំមើមផ្លែឈើ បន្លែ សម្រាប់ការហូបចុកប្រចាំថ្ងៃ សហគមន៍មូលដ្ឋានក៏ប្រមូលផលទឹកឃ្មុំព្រៃ ផ្ដៅ ឫស្សី ជ័រទឹក និង*ទ្រាំង* ប្រកបដោយនិរន្តរភាព ដើម្បីយកទៅកែច្នៃ និងលក់ផលិតផលអាហារ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃផងដែរ។

ដោយហេតុនេះ ការការពារសិទ្ធិពឹងអាស្រ័យលើធនធានព្រៃឈើរបស់សហគមន៍មូលដ្ឋាន ជាពិសេសប្រជាជនជនជាតិដើមភាគតិច មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីធានាឱ្យមានការបែងចែកអត្ថប្រយោជន៍ប្រកបដោយសមធម៌ តាមរយៈការលើកកម្ពស់ការយល់ដឹង និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ក្នុងឱកាសមានមតិទៅកាន់អ្នកពាក់ព័ន្ធសំខាន់ៗចំនួនជិត ២០០ នាក់ មកពីវិស័យព្រៃឈើ ដែលមានវត្តមានក្នុងវេទិកាថ្នាក់ជាតិលើកទីពីរស្ដីពីអនុផលព្រៃឈើនៅថ្ងៃនេះ **ឯកឧត្តម ង ឡៃ** អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃក្រសួងបរិស្ថាន មានប្រសាសន៍ថា៖ "កម្មវិធីព្រៃឈើជាតិឆ្នាំ ២០១០-២០២៩ របស់កម្ពុជាមានគោលបំណង បង្កើនការងារ ដែលនេះក៏ជាគោលដៅសំខាន់មួយនៅថ្នាក់ជាតិផងដែរ តាមរយៈសកម្មភាពការងារព្រៃឈើប្រកបដោយចីរភាព ដូចជាការប្រមូល និងការកែច្នៃអនុផលព្រៃឈើដោយប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធផល ជួយបង្កើនសង្វាក់តម្លៃ ដើម្បីជម្រុញឱ្យមានការចូលរួមពីប្រជាជនជនបទនៅក្នុងសកម្មភាពសង្គមសេដ្ឋកិច្ចរបស់ខ្លួន។"

ឯកឧត្តមមានប្រសាសន៍បន្ថែមទៀតថា៖ "កម្មវិធីជាតិនេះ គាំទ្រផងដែរដល់ការអភិវឌ្ឍសហគ្រាសជនបទខ្នាតតូចនិងមធ្យម ដែលជួយបន្ថែមតម្លៃដល់ផលិតផលព្រៃឈើ និងជាការចូលរួមចំណែកដោយផ្ទាល់ដល់វិធីសាស្ត្រនៃការគ្រប់គ្រងព្រៃឈើដោយសហគមន៍ ដែលអាចធានាបាននូវចីរភាពដោយខ្លួនឯង។"

ផលិតករអនុផលព្រៃឈើ មិនត្រឹមតែជួយលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ចក្នុងសហគមន៍របស់ខ្លួនតែប៉ុណ្ណោះទេ ប៉ុន្តែក៏អាចផ្ដោតការយកចិត្តទុកដាក់លើការការពារសមាជិកសហគមន៍ពីហានិភ័យ ឬវិបត្តិសេដ្ឋកិច្ចដែលអាចកើតមានជាយថាហេតុ ដោយការបង្កើតឱ្យមានសេវាកិច្ចគាំពារសង្គមក្រៅប្រព័ន្ធ ដូចជា ការប្រមូលផ្ដុំធនធានហិរញ្ញវត្ថុក្នុងក្រុមសន្សំ និងមូលនិធិឥណទានជាដើម។

ក្នុងការសហការជាមួយរដ្ឋាភិបាលកម្ពុជា ដៃគូអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងដៃគូមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន ដោយមានការគាំទ្រថវិកាពីគណៈកម្មាធិការ IUCN ប្រទេសហូឡង់ អង្គការ SDC និង ADB គិតមកទល់សព្វថ្ងៃនេះ បណ្ដាញ NTFP-EP កម្ពុជា បានផ្ដល់ការគាំទ្រយ៉ាងជោគជ័យ ដល់ការបង្កើតសហគ្រាសតាមសហគមន៍សរុបជាង ៦០ នៅក្នុងខេត្ត ក្រចេះ ស្ទឹងត្រែង ព្រះវិហារ មណ្ឌលគិរី រតនៈគិរី កោះកុង និងសៀមរាប។

# សេចក្តីប្រកាសសារព័ត៌មាន

**ហាមចេញផ្សាយរហូតដល់ ថ្ងៃចន្ទ ទី ១០ ខែ មិថុនា ឆ្នាំ ២០១៩**
**វេលាម៉ោង ០០.០១ ព្រឹក**

សម្រាប់ឆ្នាំ២០១៨ សកម្មភាពសហគ្រាសសង្គមទាំងនេះ គ្របដណ្តប់លើផ្ទៃដីសរុបចំនួន ៣៧៩៨៩៧,៧៤ ហិកតា ក្រោមការគ្រប់គ្រងរបស់សហគមន៍ព្រៃឈើ និងសហគមន៍ដលផលក្នុងខេត្តខាងលើ។ បណ្តាញ NTFP-EP ក៏គាំទ្រដល់អន្តរការីថ្នាក់ជាតិចំនួនមួយផងដែរ គឺក្រុមហ៊ុន *NatureWild* ដែលមានតួនាទីគាំទ្រដល់ការចែកចាយផលិតផលទៅក្នុងទីផ្សារក្នុងប្រទេស។ ក្នុងឆ្នាំ ២០១៧ ចំណូលរបស់សហគមន៍បានមកពីផលិតផលអនុផលព្រៃឈើរបស់ខ្លួន ដូចជា ទឹកឃ្មុំព្រៃ ឫស្សី ជ័រទឹក និង*ទ្រាំង* មានទឹកប្រាក់ប្រមាណ ៧៨១៨២ ដុល្លារ ហើយក្នុងឆ្នាំ ២០១៨ មានចំនួនប្រមាណ ៦៦៨៩៨ ដុល្លារ។

ស្របពេលជាមួយគ្នានេះដែរ ការចូលរួមចំណែកគួរឲ្យកត់សម្គាល់ ពីវិស័យព្រៃឈើតាមរយៈសង្វាក់នៃការផ្គត់ផ្គង់ផ្តៅ ដល់ការរីកចម្រើនសេដ្ឋកិច្ចជាតិ ត្រូវបានប៉ាន់ប្រមាណថា មានទឹកប្រាក់ចំនួន ១,៥ លានដុល្លារ។

ទោះយ៉ាងនេះក្តី ដើម្បីអាចពង្រីកផលិតកម្ម និងបង្កើនសហគ្រិនភាព ផលិតករសហគមន៍ទាំងអស់នេះចាំបាច់ត្រូវការ ការផ្តល់នូវភាពអង់អាចនិងទំនុកចិត្ត ដើម្បីប្រកួតប្រជែងក្នុងសង្វាក់ផលិតកម្មអនុផលព្រៃឈើទ្រង់ទ្រាយធំ ក៏ដូចជាត្រូវការការទទួលបាននូវអត្ថប្រយោជន៍ពីទីផ្សារធំផងដែរ។ ការគ្រប់គ្រងសហគមន៍ និងការកសាងសមត្ថភាព មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការជួយធានាឱ្យមានភាពអនុលោមតាមបទដ្ឋាន និងស្តង់ដារពាក់ព័ន្ធនានា។

ក្នុងការថ្លែងសន្ទរកថាបើកកម្មវិធីទៅកាន់អ្នកចូលរួមក្នុងវេទិកាជាតិលើកទីពីរ លោកស្រី **Femy Pinto** នាយកប្រតិបត្តិរបស់បណ្តាញ NTFP-EP Asia មានប្រសាសន៍ថា ផលិតករនៅតាមសហគមន៍ គឺជាផ្នែកមួយដ៏សំខាន់នៃវិស័យឯកជនក្នុងវិស័យអនុផលព្រៃឈើ ហេតុនេះ ពួកគេក៏ជាអ្នកដើរតួនាទីដ៏សំខាន់ផងដែរក្នុងការសម្រេចបានគោលដៅអភិរក្សព្រៃឈើ និងលុបបំបាត់ភាពក្រីក្រ ដែលជាការចូលរួមចំណែកដល់គោលដៅ អភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា (CSDGs)។

នៅក្នុងកិច្ចការបង្កើតសហគ្រាសតាមសហគមន៍សម្រាប់ការជួយគាំទ្រដល់ជីវភាពរស់នៅ ការយល់ដឹង និងពត៌មានអំពីទីផ្សារដើរតួនាទីយ៉ាងសំខាន់មួយ ក្នុងការធានាឲ្យកិច្ចការទទួលបានជោគជ័យ។ លោកស្រី PINTO បានលើកឡើងថា៖ "ជាទូទៅ ក្រុមសហគមន៍តែងព្យាយាមស្វែងរកការគាំទ្របន្ថែមទៀតពី តួអង្គសំខាន់ៗក្នុងវិស័យអភិវឌ្ឍ រួមមាន រដ្ឋាភិបាល វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីអភិវឌ្ឍសង្វាក់តម្លៃអនុផលព្រៃឈើ។"

លោកស្រីបានអំពាវនាវយ៉ាងទទូចថា៖ "មេរៀនទទួលបានពីការអនុវត្តគម្រោង ស្តែងឱ្យយើងឃើញថា គំរូវិធីសាស្ត្រចងក្រងសហគ្រាសតាមសហគមន៍ ត្រូវផ្អែកលើសង្វាក់តម្លៃដែលត្រូវដាក់បញ្ចូលគ្នា ដើម្បីអាចបញ្ជូនដល់អ្នកប្រើប្រាស់ចុងក្រោយ តាមរយៈការជម្រុញឲ្យអនុវត្តនូវវិធីសាស្ត្រក្នុងការដាក់បញ្ចូលនូវអ្នកពាក់ព័ន្ធពហុវិស័យឬការភ្ជាប់ទំនាក់ទំនងរវាងសហគ្រាសទាំងនេះទៅនឹងសង្វាក់តម្លៃរបស់សហគ្រាសខ្នាតធំ"។

ជាការពិតណាស់ថា ខ្សែសង្វាក់ផលិតកម្មអនុផលព្រៃឈើ ត្រូវអាស្រ័យជាខ្លាំងលើធនធានធម្មជាតិដែលមានការគ្រប់គ្រងប្រកបដោយចីរភាព។ ប៉ុន្តែ ដូចបណ្តាប្រទេសដទៃទៀតក្នុងទ្វីបអាស៊ីដែរ ដែលសេដ្ឋកិច្ចកំពុងមានការរីកចម្រើននោះ ធនធានធម្មជាតិរបស់កម្ពុជាកំពុងត្រូវបានប្រើប្រាស់ក្នុងលក្ខខណ្ឌគ្មាននិរន្តរភាព ដោយសារតែការ

**សេចក្តីប្រកាសសារព័ត៌មាន**

**ហាមចេញផ្សាយរហូតដល់ ថ្ងៃចន្ទ ទី ១០ ខែ មិថុនា ឆ្នាំ ២០១៩**
**វេលាម៉ោង ០០.០១ ព្រឹក**

គិតតែពីផលចំណេញរយៈពេលខ្លី ដូចជា ការកាប់ព្រៃឈើខុសច្បាប់ ការជួញដូរសត្វព្រៃ ការនេសាទខុសច្បាប់ ការបង្វែរដីព្រៃទៅជាដីសម្បទានសេដ្ឋកិច្ចសម្រាប់ចម្ការដំណាំ ការបំផ្លិចបំផ្លាញព្រៃឈើដើម្បីទាញយកផលរ៉ែ និងកត្តាគំរាមកំហែងដទៃទៀត។

លោកស្រី **Diane Caroen** ប្រធានក្រុមការងារគម្រោង LISDI របស់អង្គការ WWF កម្ពុជា បានមានប្រសាសន៍ថា៖ "ដើម្បីឱ្យការងារគ្រប់គ្រងព្រៃឈើតាមសហគមន៍ក្នុងប្រទេសកម្ពុជាទទួលបានជោគជ័យ ការរួមបញ្ចូលគ្នារវាងមនុស្ស សេដ្ឋកិច្ច និងការអភិរក្សធនធានធម្មជាតិចាំបាច់ត្រូវតែជាធាតុស្នូលនៃគ្រប់គោលនយោបាយព្រៃឈើទាំងអស់ ហើយស្របពេលជាមួយគ្នានោះ សិទ្ធិដីធ្លី និងដីព្រៃស្ថិតក្រោមការគ្រប់គ្រងរបស់សហគមន៍ ចាំបាច់ត្រូវបានទទួលការការពារពីច្បាប់ ហើយត្រូវបានធានានិងពង្រឹងការអនុវត្តដោយអាជ្ញាធររដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ក្រោមការបន្តគាំទ្រពី អង្គការអន្តរជាតិ អង្គការក្នុងស្រុក និងទីភ្នាក់ងារជំនួយការអភិវឌ្ឍនានា។"

ជាផ្នែកមួយនៃការគាំទ្រចំពោះសហគមន៍ដែលពឹងអាស្រ័យលើផលិតផលអនុផលព្រៃឈើ អង្គការ WWF និងដៃគូ WCS បានសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន នៅក្នុងគម្រោងច្រករបៀងអភិវឌ្ឍជីវៈចម្រុះក្នុងមហាអនុតំបន់ទន្លេមេគង្គ ផ្តល់មូលនិធិដោយ ADB ដើម្បីអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់ជីវភាពរស់នៅ និងពង្រីកសកម្មភាពរបស់ខ្លួនក្នុងការលើកកម្ពស់សង្វាក់តម្លៃអនុផលព្រៃឈើក្នុងខេត្តកោះកុង និងមណ្ឌលគិរី ( ទឹកឃ្មុំព្រៃ ឬស្សី ឱសថបុរាណជាតិ)។ យើងមានភាពជាដៃគូប្រកបដោយផ្លែផ្កាជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលមានជំនាញឯកទេស ហើយយើងព្យាយាមពង្រឹងសមាគមធុរកិច្ចរបស់សហគមន៍តំបន់ការពារ/សហគមន៍ព្រៃឈើ ក៏ដូចជាសមាគមស្វែងរកទីផ្សារជាអ្នកមៅការបន្ត ក្នុងការកសាងទំនាក់ទំនងរវាងសហគមន៍ជាមួយសហគ្រាសខ្នាតតូច និងមធ្យម។

លោកស្រី CAROEN បានបញ្ជាក់បន្ថែមទៀតថា៖ "កិច្ចខិតខំទាំងនេះនឹងអនុញ្ញាតឱ្យប្រជាជនក្នុងមូលដ្ឋានអាចធ្វើការសម្រេចចិត្តថាតើ ការប្រើប្រាស់ដី និងធនធានសហគមន៍របស់ខ្លួនអាចត្រូវប្រើប្រាស់យ៉ាងណាឱ្យប្រសើរបំផុត និងមានផលិតភាពបំផុត ដើម្បីឱ្យពួកគេអាចបន្តទទួលបានការអត្ថប្រយោជន៍លើកទឹកចិត្តផ្នែកសង្គមកិច្ច និងផ្នែកបរិស្ថានក្នុងពេលបច្ចុប្បន្ន ក៏ដូចជាសម្រាប់ពេលអនាគតវែងឆ្ងាយខាងមុខ"។

ក្រុមការងារ NTFP កម្ពុជាជាសកម្មភាពការងារស្ម័គ្រចិត្តដែលមានសមាសភាពអ្នកជំនាញជាតំណាងមកពីរដ្ឋាភិបាល ផលិតករ/សហគ្រិនសហគមន៍ អង្គការសង្គមស៊ីវិល និងអ្នកស្រាវជ្រាវ នឹងពិភាក្សាលើអនុសាសន៍នានាដែលទទួលបានពីវេទិកាជាតិនេះ ដើម្បីកសាងជាផែនការសកម្មភាពសម្រាប់ការអនុវត្តពេលខាងមុខ។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**
**លោក គួយ សុជាតិ**
មន្ត្រីព័ត៌មាននិងកិច្ចការសាធារណៈ
ការិយាល័យបណ្តាញ NTFP-EP កម្ពុជា
ទូរស័ព្ទ: ០៩២ ២៩២ ៣៣៨ / ០១០ ២៩២៣៣៨ / ០៦៨ ៧១ ៧២ ៨៣ និង អ៊ីម៉ែល៖ socheat@ntfp.org

# សេចក្តីប្រកាសសារព័ត៌មាន

**ហាមចេញផ្សាយរហូតដល់ ថ្ងៃចន្ទ ទី ១០ ខែ មិថុនា ឆ្នាំ ២០១៩**
**វេលាម៉ោង ០០.០១ ព្រឹក**

**កំណត់សម្គាល់សម្រាប់កាវីនិពន្ធ៖**

- **តើអ្វីជាផលិតផលអនុផលព្រៃឈើ?** ផលិតផលអនុផលព្រៃឈើ ត្រូវបានកំណត់និយមន័យថាជា ធនធានជីវសាស្ត្រមិនមែនជាឈើ ដែលត្រូវបានដកហូតចេញពីព្រៃសម្រាប់ការប្រើប្រាស់របស់មនុស្ស។ ឧទាហរណ៍អំពីអនុផលព្រៃឈើមានដូចជា ផ្លែឈើ និងគ្រាប់ឈើ បន្លែ គ្រឿ រុក្ខជាតិឱសថ ទឹកឃ្មុំព្រៃ ជ័រទឹក សំបកឈើ និងរុក្ខជាតិសរសៃផ្សេងៗជាច្រើនទៀតដូចជា ឬស្សី ផ្តៅ ក៏ដូចជាត្នោត និងស្មៅផ្សេងៗជាដើម។
- **អំពីវេទិកាជាតិស្តីពីអនុផលព្រៃឈើ៖** វេទិកាជាតិស្តីពីអនុផលព្រៃឈើ ត្រូវបានផ្តួចផ្តើមឡើងក្នុងបំណង ដើម្បីបង្ហាញអំពីលទ្ធផល និងការអនុវត្តជោគជ័យដែលសហគមន៍មូលដ្ឋានសម្រេចបានក្នុងការអភិវឌ្ឍ និងលើកកម្ពស់សង្វាក់តម្លៃផលិតកម្ម ដោយប្រើប្រាស់ការអនុវត្តក្នុងការប្រមូលផល និងការកែច្នៃដែលគោរពស្តង់ដារបរិស្ថាន។ កិច្ចខិតខំនៅថ្នាក់សហគមន៍ទាំងអស់នេះ គាំទ្រដល់ការប្រើប្រាស់ និងការគ្រប់គ្រងអនុផលព្រៃឈើ និងធនធានព្រៃឈើប្រកបដោយចីរភាពនៅក្នុងតំបន់គ្រប់គ្រងសហគមន៍របស់ខ្លួន ហើយស្របពេលជាមួយគ្នានោះ សកម្មភាពនេះក៏ចូលរួមចំណែកក្នុងការលើកកម្ពស់ផ្នែកសង្គមសេដ្ឋកិច្ចរបស់គ្រួសារក្នុងសហគមន៍មូលដ្ឋានផងដែរ។

  វេទិកាជាតិស្តីពីអនុផលព្រៃឈើលើកទីមួយ ត្រូវបានរៀបចំឡើងក្នុងឆ្នាំ ២០១៥ ដោយបានលើកកម្ពស់សារៈសំខាន់នៃអនុផលព្រៃឈើ និងបានចាប់ផ្តើមបង្ហាញឱ្យឃើញនូវលទ្ធផលគួរជាទីមោទនៈ ក្នុងការអភិវឌ្ឍសង្វាក់តម្លៃអនុផលព្រៃឈើក្នុងប្រទេសកម្ពុជា។ ក្នុងវេទិកាជាតិលើកទីពីរនេះ យើងនឹងពន្លេចឱ្យឃើញនូវវឌ្ឍនភាពជាបន្តបន្ទាប់ ដែលត្រូវបានធ្វើឡើងក្នុងការអភិវឌ្ឍសង្វាក់តម្លៃអនុផលព្រៃឈើ ដូចជា ការបង្កើតឱ្យមានជាស្តង់ដារសម្រាប់ការអនុវត្តការគ្រប់គ្រងអនុផលព្រៃឈើ និងការពង្រីកគំរូសហគ្រាសសហគមន៍លើមុខទំនិញអនុផលព្រៃឈើផ្សេងៗជាច្រើន ដូចជា ទឹកឃ្មុំព្រៃ ផ្តៅ ឬស្សី ជ័រទឹក និង*ទ្រាំង* ជាដើម។
- ដៃគូសម្រាប់ព្រៃឈើ និងជលផល (PAFF)។ ការអភិវឌ្ឍ និងការអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់ជីវភាពរស់នៅ (LISDI)ផ្តល់មូលនិធិដោយ ADB ។ ធនធានរួម ដំណោះស្រាយរួម (SRJS) សម្រាប់ IUCN គាំទ្រគម្រោងច្រករបៀងអភិរក្សជីវចម្រុះ។
- **អំពីបណ្តាញ NTFP-EP៖** NTFP-EP គឺជាបណ្តាញសហការគ្នារបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍ជាង ៦០ ដែលធ្វើការជាមួយសហគមន៍ព្រៃឈើ ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពនៅក្នុងប្រទេសហ្វីលីពីន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម និងកម្ពុជា។ ក្នុងប្រទេសកម្ពុជា បណ្តាញ NTFP-EP បានធ្វើការងារតាំងពីឆ្នាំ ២០០៧ មកជាមួយរាជរដ្ឋាភិបាលកម្ពុជា ផលិតករអនុផលព្រៃឈើ និងសហគ្រិន វិស័យឯកជន អង្គការសង្គមស៊ីវិល និងវិស័យសិក្សាស្រាវជ្រាវ លើការអភិវឌ្ឍសង្វាក់តម្លៃអនុផលព្រៃឈើ និងលើកម្ពស់ការគ្រប់គ្រងព្រៃឈើ និងជលផលនៅតាមសហគមន៍។